# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ៧០៤៥ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

**-ឯកឧត្តមទេសរដ្ឋមន្ត្រីប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**-ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

**-ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**-ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងព័ត៌មាន**

**កម្មវត្ថុ**៖ ករណីសំណើសុំរាជរដ្ឋាភិបាលចេញគោលនយោបាយ ៧ ចំណុច ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ។

**យោង** ៖ -លិខិតលេខ ៣៦៦ អ.ជ.ប.ជ.អ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០១៣ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

-ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា៖ រាជរដ្ឋាភិបាលបានឯកភាពដាក់ចេញជាគោលនយោបាយ ៧ ចំណុច ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ដូចខាងក្រោម៖

១- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តសហការជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលផង ជំរុញ និងលើកទឹកចិត្តឲ្យមានការប្រើស្រោមអនាម័យឲ្យបាន១០០% ដើម្បីសុវត្ថិភាពក្នុងការរួមភេទ ឲ្យរួចចាកការឆ្លងកាមរោគ និងមេរោគអេដស៍។

២- បញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ និងសុខភាពមាតា ជាចំណុចបន្ថែមនៃគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព។

៣- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួងសុខាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ រួមទាំងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ត្រូវសហការគ្នារៀបចំផែនទីបញ្ជាក់ពី ភូមិសាស្ត្រ ចំនួនអ្នកផ្ទុកមេរោគអេដស៍ ក្រុមជនងាយ

រងគ្រោះ មាន៖ នារីបំរើសេវាកំសាន្ត បុរសស្រឡាញ់បុរស កុមារកំព្រាដែលឪពុកម្តាយស្លាប់ដោយជំងឺអេដស៍ ជនចំណាកស្រុកដែលផ្ទុកមេរោគអេដស៍ ចំនួននិងទីកន្លែង មន្ទីរផ្តល់សេវាព្យាបាលជំងឺអេដស៍។

៤- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវចាត់វិធានការធ្វើឲ្យគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ឃុំ/សង្កាត់ មានសកម្មភាពឡើងវិញ។ ក្រសួងសុខាភិបាល ត្រូវណែនាំដល់មន្ទីរសុខាភិបាលខេត្តនីមួយៗ ឲ្យសហការជិតស្និទ្ធជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខេត្ត ក្នុងការងារប្រយុទ្ធនឹងជំងឺអេដស៍។ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តនីមួយៗ ត្រូវពង្រឹងលក្ខណៈជាដៃគូជាមួយអង្គការសង្គមស៊ីវិលដែលកំពុងដំណើរការនៅក្នុងខេត្តរបស់ខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់។

៥- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវសហការគ្នា ដើម្បីអនុញ្ញាតឲ្យជនងាយរងគ្រោះដោយជំងឺអេដស៍ ដែលមានជាអាទិ៍៖ នារីបំរើសេវាកំសាន្ត បុរសស្រឡាញ់បុរស អ្នកញៀនគ្រឿងញៀនប្រើម្ជុល អាចទទួលបានសេវាព្យាបាលជំងឺអេដស៍បានយ៉ាងទូលំទូលាយ។

៦- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយ ក្រសួង អប់រំ យុវជន និងកីឡា អង្គការយុវជន ស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កើនការអប់រំដល់យុវជន យុវនារី ឲ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និងវិធីបង្ការ ការពារឲ្យបានទូលំទូលាយ។

៧- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំ សម្របសម្រួល និងតាមដានការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ស្របតាមការចង្អុលបង្ហាញរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមុខនាទីដឹកនាំ និងទទួលខុសត្រូវលើប្រសិទ្ធភាពនៃជំនួយសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទូទាំងប្រទេស។ ក្រសួងមន្ទីរពាក់ព័ន្ធ រាជធានី និងខេត្ត ត្រូវសហការគ្នារៀបចំកម្មវិធី ការងារប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីកែសម្រួលការប្រើប្រាស់ធនធាន ដែលបានទទួលពីគ្រប់មជ្ឈដ្ឋាន ឲ្យបានលទ្ធផលជាក់ស្តែង ប្រសិទ្ធភាព ប្រសិទ្ធិផល និងឈានទៅធានានិរន្តរភាព ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងទទួលចាត់ចែងអនុវត្តតាមការគួរ។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ម៉ៅ ហាវណ្ណាល់**

**ចម្លងជូន ៖**

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-សាលារាជធានី ខេត្ត

-ឯកសារ-កាលប្បវត្តិ